កិច្ចការ១៧:១-២១

# ជំពូក១៧

***បាឋចនា*** *កំណត់សម្គាល់*

*កិច្ចការសាវ័កប៉ុលនៅក្រុងថែស្សាឡូនីច*

*កិច្ចការសាវ័កប៉ុលនៅក្រុងបេរា*

*កិច្ចការសាវ័កប៉ុលនៅក្រុងអាថែន*

## កំណត់សម្គាល់

នៅក្នុងជំពូក១៧ យើងបន្តការសិក្សាពីដំណើរបេសកកម្មលើកទីពីររបស់សាវ័កប៉ុល។ ជំពូក១៦ សាវ័កប៉ុលធ្វើដំណើរឆ្លងទ្វីបអាស៊ី នាំដំណឹងល្អចូលទៅក្នុងទ្វីបអឺរ៉ុប។ បើសាវ័កប៉ុលមិនបានធ្វើដំណើរបេសកកម្មឆ្លងទ្វីបនេះទេ ម្ល៉េះសមទ្វីបអឺរ៉ុបសព្វថ្ងៃ មិនបានស្ថិតនៅក្រោមឥទ្ធិពលដំណឹងល្អដូចយើងឃើញនេះឡើយ។ តាមគម្ពីរកិច្ចការ យើងអាចអះអាងថា ជនជាតិស្បែកសពីដើម មិនមែនជាគ្រីស្ទបរិស័ទទេ។ គ្រីស្ទបរិស័ទមានដើមកំណើតនៅទ្វីបអាស៊ី។ ពួកគ្រីស្ទបរិស័ទជំនាន់សតវត្សរ៍ទីមួយបាននាំដំណឹងល្អពីទ្វីបអាស៊ីទៅទ្វីបអឺរ៉ុប។ ដូច្នេះបានជាប្រទេសនានានៅទ្វីបអឺរ៉ុបស្ថិត

នៅក្រោមឥទ្ធិពលដំណឹងល្អព្រះយេស៊ូវ។ ដូច្នេះ បើយើងសន្និដ្ឋានថា សាសនាគ្រីស្ទ ជាសាសនារបស់ជនជាតិស្បែកស មិនត្រឹមត្រូវទេ។ តាមពិតទៅសាសនាគ្រីស្ទ គឺជាសាសនារបស់ពួកអាស៊ី។ យើងអរព្រះគុណដល់ព្រះអង្គ ដែលទ្រង់បានប្រទានអោយមានដំណឹងល្អបានធ្លាក់ទៅដល់សាសន៍អឺរ៉ុប។

នៅពេលសាវ័កប៉ុលធ្វើដំណើរទៅដល់ទ្វីបអឺរ៉ុប លោកស្នាក់នៅទីក្រុងតូចមួយ ឈ្មោះទីក្រុងភីលីព។ ដំបូងឡើយ អ្នកនៅទីក្រុងនោះ មិនរាប់អានសាវ័កប៉ុលទេ។ ប៉ុន្តែទោះជាយ៉ាងនោះក៏ដោយ សាវ័កប៉ុលបានបង្កើតក្រុមជំនុំតូចមួយនៅទីក្រុងភីលីពនេះ។ សាវ័កប៉ុលមានភាពជិតស្និទ្ធជាមួយនឹងពួកជំនុំនៅទីក្រុងភីលីព ជាងក្រុមជំនុំណាៗទាំងអស់ក្នុងទ្វីបអឺរ៉ុប។

ឥឡូវលោកបន្តដំណើរចូលកាន់តែជ្រៅទៅក្នុងទ្វីបអឺរ៉ុបហើយ។ លោកធ្វើដំណើរទៅទីក្រុងថែស្សាឡូនីច ទីក្រុងបេរា រួចហើយបន្តដំណើរឆ្ពោះទៅទិសខាងលិច គឺទៅទីស្រុកម៉ាសេដូន ហើយនិងបែរមកទិសខាងត្បូង គឺទីក្រុងអាថែន។ ទីក្រុងថែស្សាឡូនីច គឺជាកន្លែងដែលលោកបំពេញបេសកកម្មបានយ៉ាងខ្លាំងក្លា ក្នុងការផ្សាយដំណឹងល្អរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

# កិច្ចការសាវ័កប៉ុល នៅក្រុងថែស្សាឡូនីច

**រីឯកាលបានដើរកាត់ក្រុងអាំភីប៉ូលី នឹងក្រុងអ័ប៉ុឡូនា នោះគេទៅដល់ក្រុងថែស្សាឡូនីច ជាកន្លែងដែលមានសាលាប្រជុំរបស់សាសន៍យូដា (កិច្ចការ១៧:១)។**

ដូចយើងជម្រាបរួចមកហើយថា នៅពេលសាវ័កប៉ុលធ្វើដំណើរទៅដល់ទីណា លោកតែងតែសំដៅទៅរកសាលាប្រជុំរបស់សាសន៍យូដាសិន។ លុះលោកបានបង្រៀនសព្វគ្រប់ហើយ លោកក៏ចេញពីសាលាប្រជុំសាសន៍យូដា ដើម្បីផ្សព្វផ្សាយដំណឹងល្អដល់អ្នកស្រុក ដែលនៅជុំវិញក្រវល់សាលាប្រជុំនោះ។ ការផ្សព្វផ្សាយដំណឹងល្អនៅសាលាប្រជុំរបស់សាសន៍យូដា ធ្វើអោយសាសន៍យូដាខ្លះជឿដល់ព្រះអម្ចាស់យេស៊ូវ។ ប៉ុន្តែមានសាសន៍យូដាខ្លះ មិនព្រមទទួលដំណឹងល្អរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទទេ។ ឆ្លៀតពេលនោះ សាវ័កប៉ុលក៏ផ្សព្វផ្សាយដំណឹងល្អដល់សាសន៍ដទៃទៅ។ ពេលសាវ័កប៉ុលអធិប្បាយ មានសាសន៍ដទៃច្រើនណាស់ បានជឿដល់ដំណឹងល្អរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ដូច្នេះ ក្រុមជំនុំនៅទ្វីបអឺរ៉ុប ច្រើនតែជាក្រុមជំនុំដែលមានសាសន៍យូដាផង សាសន៍ដទៃផងចូលរួម។

ទីក្រុងអាំភីប៉ូលី ប្រែថា ទីក្រុងមានទ្វារប្រាំបួន។

ទីក្រុងមានទ្វារប្រាំបួន ជាទីក្រុងដែលរាជការរ៉ូមយកធ្វើជាមណ្ឌលយុទ្ធសាស្ត្រផង ជាមណ្ឌលពាណិជ្ជកម្មផង។ ធម្មតាទីក្រុងសម័យនោះ គេសង់ជារាងបួនជ្រុង តែទីក្រុងអាំភីប៉ូលី មានកំផែងរាងមូល ឯរបងព័ទ្ធជុំវិញក៏មូលដែរ។ ទីក្រុងនេះស្ថិតនៅលើមហាវិថីមួយរបស់សាសន៍រ៉ូម ដែលភ្ជាប់ទ្វីបអឺរ៉ុបទៅទ្វីបអាស៊ី។ ទាហានរ៉ូមតែងតែអូសកងទ័ពរបស់ខ្លួនតាមមហាវិថីនេះ នៅពេលធ្វើដំណើរទៅ និងមកពីទីក្រុងរ៉ូម។ ឯផ្លូវនោះទៀតសោត ជាផ្លូវដែលពួកពាណិជ្ជករធ្វើដំណើរពីទ្វីបអឺរ៉ុបទៅ ទ្វីបអាស៊ី និងទ្វីបអាហ្វ្រិកដែរ។ សាវ័កប៉ុលក៏ធ្វើដំណើរតាមផ្លូវធំនោះចុះទៅទីក្រុងថែស្សាឡូនីច។ ទីក្រុងមួយទៀត ដែលលោកឈប់សំចតនៅពេលធ្វើដំណើរតាមផ្លូវនោះ គឺទីក្រុងអ័ប៉ុឡូនា។

ទីក្រុងថែស្សាឡូនីច មានចម្ងាយប្រមាណហុកសិបមួយគីឡូម៉ែត្រ ខាងលិចទីក្រុងអ័ប៉ុឡូនា តាមបណ្ដោយមហាវិថីនោះ។ ទីក្រុងនោះ ស្ថិតនៅចូលជ្រៅទៅក្នុងប្រទេសទាំងមូល។ ប៉ុន្តែដោយសារមានដៃសមុទ្របីទៅជួបគ្នានៅទីក្រុងនោះ គេបានសង់កំពង់ផែមួយយ៉ាងធំ។ ទីក្រុងថែស្សាឡូនីចដ៏ធំ ស្ថិតនៅក្រោមអាណានិគមរបស់សាសន៍រ៉ូម។ នៅឆ្នាំ៣១៥មុនគ្រិស្តសករាជ មានមេទ័ពរបស់សាសន៍រ៉ូម បានសង់ទីក្រុងនេះឡើង រួចហើយដាក់ឈ្មោះថា ក្រុងថែស្សាឡូនីច តាមឈ្មោះប្អូនស្រីរបស់មេទ័ពមួយរូបទៀត គឺមហារាជ្យអាឡិចហ្សែនឌ័រ។ ទីក្រុងថែស្សាឡូនីចនេះ មានទឹកក្ដៅផុសចេញមកមិនចេះអស់ឡើយ។ ដូច្នេះ មេទ័ពមួយរូបរបស់មហារាជ្យអាឡិចហ្សែនឌ័រ បានគ្រប់គ្រងទីក្រុងនេះ បន្ទាប់ពីមេទ័ពរូបនេះស្លាប់ទៅ។ នៅពេលដែលសាវ័កប៉ុលធ្វើ

ដំណើរទៅផ្សព្វផ្សាយដំណឹងល្អនៅទីក្រុងថែស្សាឡូនីច ទីក្រុងនេះ ស្ថិតនៅក្រោមការត្រួតត្រារបស់សាសន៍រ៉ូម។

> **[២] ប៉ុលក៏ចូលទៅឯគេតាមទំលាប់គាត់ ហើយជជែកពន្យល់ដល់គេតាមគម្ពីរ ក្នុង៣ថ្ងៃឈប់សំរាក [៣] ក៏បើកសំដែងយ៉ាងច្បាស់ថា ព្រះគ្រីស្ទត្រូវតែរងទុក្ខ រួចមានព្រះជន្មរស់ពីស្លាប់ឡើងវិញ គាត់ក៏និយាយថា ព្រះយេស៊ូវនេះឯង ដែលខ្ញុំប្រកាសប្រាប់ដល់អ្នករាល់គ្នា ទ្រង់ជាព្រះគ្រីស្ទនោះហើយ (កិច្ចការ១៧:២-៣)។**

ទីណាដែលលោកអញ្ជើញទៅដល់ លោកប៉ុលតែងតែចូលទៅផ្សាយដំណឹងល្អ នៅសាលាប្រជុំរបស់សាសន៍យូដា។ សាវ៉ែកប៉ុលស្នាក់នៅទីក្រុងថែស្សាឡូនីចអស់រយៈពេលបីសប្តាហ៍ ទោះបីពេលវេលាតិចដែលលោកស្នាក់នៅទីនោះ លោកបានបង្កើតក្រុមជំនុំមួយក្រុមនៅទីនោះដែរ។ ពួកអ្នកជឿដល់ព្រះអម្ចាស់យេស៊ូវប្រមូលគ្នាធ្វើជាក្រុមជំនុំ រួចហើយសាវ៉ែកប៉ុលជួយរៀបចំអោយមានមេអ្នកដឹកនាំនៅក្នុងវិហារនោះ។ មិនតែប៉ុណ្ណោះ សាវ៉ែកប៉ុលខំបង្ហាត់បង្រៀនព្រះបន្ទូលដល់គេ នៅក្នុងរយៈពេលដ៏ខ្លី។ សាវ៉ែកប៉ុលបង្រៀនគោលទ្ធិបទគម្ពីរ ពោលគឺជាគោលទ្ធិនៃព្រះអម្ចាស់យេស៊ូវសុគតនឹងរស់ឡើងវិញ។ លោកបង្ហាត់បង្រៀនដល់ពួកជំនុំអោយយល់អំពីគ្រាមហាសោមនស្ស ពោលគឺជាគ្រាដែលព្រះជាម្ចាស់ទ្រង់យាងមកប្រមូលពួកជំនុំរបស់

ព្រះអង្គ ទៅនៅជាមួយនឹងទ្រង់។ បើយើងសិក្សាសំបុត្រទីមួយរបស់សាវ័កប៉ុលផ្ញើទៅកាន់ពួកជំនុំទីក្រុងថែស្សាឡូនីច យើងឃើញថា សេចក្តីនោះសុទ្ធតែសម្តែងអំពីគោលទ្និនៅក្នុងព្រះគម្ពីរ។ សាវ័កប៉ុលស្ថិតនៅទីក្រុងថែស្សាឡូនីច តិចជាងមួយខែ ប៉ុន្តែលោកសម្រេចការបានជាច្រើន។

លោកបង្ហាត់បង្រៀនដល់ពួកជំនុំ ដែលទើបនឹងចាប់ផ្តើមថា "...ព្រះគ្រីស្ទត្រូវតែរងទុក្ខ រួចមានព្រះជន្មរស់ពីសុគតឡើងវិញ"។ លោកបញ្ជាក់ទៀតថា "...ព្រះយេស៊ូវនេះឯង ដែលខ្ញុំប្រកាសប្រាប់ដល់អ្នករាល់គ្នា ទ្រង់ជាព្រះគ្រីស្ទនោះហើយ"។ ទ្រង់ជាព្រះគ្រីស្ទ ដ្បិតសាសន៍យូដានៅក្នុងព្រះគម្ពីរសញ្ញាចាស់ តែងតែរង់ចាំព្រះអង្គសង្គ្រោះមួយអង្គយាងមកលោះគេអោយរួចពីបាប។ ប៉ុន្តែការរង់ចាំរបស់សាសន៍យូដាមិនបានយល់ថា អង្គព្រះគ្រីស្ទដែលយាងមកសុគត រួចហើយរស់ឡើងវិញ គឺជាអង្គដែលគេរង់ចាំនោះទេ។ ដូច្នេះ សាវ័កប៉ុលយកសេចក្តីរង់ចាំរបស់មនុស្សនៅក្នុងគម្ពីរសញ្ញាចាស់ មកពន្យល់អោយឃើញថា អង្គព្រះគ្រីស្ទគឺជាតួព្រះដែលគេរង់ចាំនោះហើយ។ សាវ័កប៉ុលនិងសាវ័កពេត្រុសតែងតែអធិប្បាយពីព្រះអម្ចាស់យេស៊ូវទ្រង់សុគត និងរស់ឡើងវិញ។

បច្ចុប្បន្នយើងរាប់ថាជាការអកុសល ពីព្រោះការរស់ឡើងវិញ របស់ព្រះអម្ចាស់យេស៊ូវមិនបានយកធ្វើជាបេះដូងនៃការអធិប្បាយរៀងរាល់សប្តាហ៍ទេ។ យើងសង្កត់ធ្ងន់ទៅលើឈើឆ្កាង។ តាមពិតទៅឈើឆ្កាងក៏ជាមូលដ្ឋានគ្រឹះរបស់គ្រីស្ទបរិស័ទដែរ។ ប៉ុន្តែ សេចក្តីសុគតរបស់ព្រះអម្ចាស់យេស៊ូវ មិនមែនសុគតជាប់រហូតដូចជា

មនុស្សដទៃទៀតទេ។ សុគតនៅលើឈើឆ្កាងមែន ប៉ុន្តែព្រះសពព្រះយេស៊ូវត្រូវគេយក ចុះពីលើឈើឆ្កាង ទៅបញ្ចុះនៅក្នុងផ្នូរបីថ្ងៃ រួចហើយបីថ្ងៃកន្លងទៅ ព្រះអម្ចាស់យេស៊ូវ ទ្រង់រស់ពីសុគតឡើងវិញ។ បច្ចុប្បន្ននេះ ព្រះអម្ចាស់យេស៊ូវគង់នៅពេញដោយសិរីល្អ ខាងស្តាំព្រះវរបិតា។ ព្រះអម្ចាស់យេស៊ូវពិតជាបានយាងមកនៅក្នុងប្រវត្តិសាស្ត្ររបស់ មនុស្សលោកអស់រយៈពេលជាង២០០០ឆ្នាំមកមែន។ ទ្រង់យាងមកសុគតនៅលើឈើ ឆ្កាង ប៉ុន្តែបីថ្ងៃក្រោយមក ទ្រង់រស់ឡើងវិញ។ ការរស់ឡើងវិញរបស់ព្រះអម្ចាស់ យេស៊ូវ ត្រូវតែជាបេះដូងនៃដំណឹងល្អ ដែលយើងគ្រប់គ្នាផ្សព្វផ្សាយពីទ្រង់។ ព្រះអង្គ ពិតជាយាងមកសុគតនៅលើឈើឆ្កាង រួចហើយរស់ឡើងវិញមែន។ តើលោកអ្នកមាន ទំនាក់ទំនងយ៉ាងដូចម្តេច ជាមួយនឹងព្រះអង្គ? សាវ័កប៉ុលបង្ហាត់បង្រៀនថា មនុស្ស លោកចាំបាច់ត្រូវបង្កើតទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងព្រះអម្ចាស់យេស៊ូវ ពោលគឺ ត្រូវជឿថា ជាព្រះអង្គដែលទ្រង់យាងមកសង្គ្រោះមនុស្សមានបាប ដោយសុគតនៅ លើឈើឆ្កាង និងរស់ឡើងវិញ។ លោកបង្ហាត់បង្រៀនចំណុចនេះយ៉ាងខ្លាំង ដល់ពួកជំនុំ នៅទីក្រុងកាឡាទី។ តើទំនាក់ទំនងរបស់លោកអ្នកជាមួយនឹងព្រះអម្ចាស់យេស៊ូវ ដែល ជាព្រះដ៏រស់មានលក្ខណៈបែបណាដែរ? បើលោកអ្នកនិយាយថា លោកអ្នកជឿដល់ ព្រះអម្ចាស់យេស៊ូវ តើទ្រង់ដែលរស់នៅក្នុងជីវិតរបស់លោកអ្នក កំពុងធ្វើអោយជីវិត របស់លោកអ្នកល្អតលាស់ឆ្ពោះទៅកាន់ភាពសុចរិតដែរឬទេ?

នៅក្នុងក្រុមជំនុំរបស់ព្រះយេស៊ូវសព្វថ្ងៃ មានអ្នកដែលប្រកាន់គោលទ្និតម្ពីរ បែបអភិរក្ស និងមានអ្នកប្រកាន់គោលទ្ធិព្រះគម្ពីរបែបសេរី។ ក្រុមទាំងពីរមិនមាន

ទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងព្រះអម្ចាស់យេស៊ូវ ដូចខ្លួនបានអះអាងនោះទេ។ ហេតុអ្វីបានជាសូម្បីក្រុមអភិរក្ស ក៏មិនមានការស្និទ្ធស្នាលជាមួយនឹងព្រះអម្ចាស់យេស៊ូវគ្រីស្ទដែរ? ធម្មតារៀងរាល់ថ្ងៃអាទិត្យ យើងត្រូវតែថ្វាយបង្គំព្រះអង្គ ដោយជឿជាក់ថាព្រះអម្ចាស់យេស៊ូវទ្រង់រស់ឡើងវិញ។ ដូច្នេះ ទោះបីក្រុមអភិរក្ស ឬក្រុមសេរី ដែលនាំគ្នាថ្វាយបង្គំព្រះអង្គនៅថ្ងៃអាទិត្យ មិនបានភ្ជាប់ព្រលឹង ភ្ជាប់បាច់ជីវិត ភ្ជាប់ខ្លួនទៅនឹងព្រះយេស៊ូវដែលរស់ឡើងវិញទេ ការថ្វាយបង្គំនោះ រាប់ថាជាការសៅហ្មងដល់ព្រលឹងខ្លួនហើយ។ នៅក្នុងក្រុមជំនុំយើងមិនចាំបាច់ប្រកាសថាយើងជាអ្នកអភិរក្ស ឬសេរីនោះទេ។ សំណួរដែលសំខាន់បំផុតនោះគឺ តើទំនាក់ទំនងរបស់យើងជាមួយនឹងព្រះអម្ចាស់យេស៊ូវ ជាទំនាក់ទំនងដែលដឹងថាទ្រង់រស់ឡើងវិញពិត ឬមួយយ៉ាងណា?

យើងមិនសូវឃើញអ្នកប្រាជ្ញគម្ពីរ យករឿងព្រះអម្ចាស់យេស៊ូវរស់ពីសុគតឡើងវិញ មកបញ្ជាក់ន័យអោយច្បាស់លាស់ទេ។ បើយើងអានអត្ថបទផ្សេងៗរបស់អ្នកប្រាជ្ញគម្ពីរដូចជា បណ្ឌិតស្រ្តុង បណ្ឌិតស្ទែត បណ្ឌិតធនវ៉ល បណ្ឌិតហាជ្យ៍ជាដើម យើងឃើញថា គេរៀបរាប់អំពីសេចក្តីសុគតរបស់ព្រះអម្ចាស់យេស៊ូវយ៉ាងវែងអន្លាយ។ ប៉ុន្តែអត្ថបទដែលគេនិយាយអំពីព្រះអម្ចាស់យេស៊ូវរស់ពីសុគតឡើងវិញ មានតែមួយឬពីរទំព័រប៉ុណ្ណោះ។ ខ្ញុំយល់ថា បើយើងមិនសង្កត់ន័យអោយបានជ្រាលជ្រៅ ស្តីអំពីព្រះអម្ចាស់យេស៊ូវរស់ឡើងវិញនោះទេ យើងមិនបានអធិប្បាយព្រះបន្ទូលព្រះអង្គអោយបានល្អិតល្អន់ឡើយ។ សេចក្តីរស់ឡើងវិញរបស់ព្រះអម្ចាស់យេស៊ូវ គឺជាបេះដូងនៃដំណឹងល្អ។ ដូច្នេះ យើងត្រូវសង្កត់ន័យនេះអោយធ្ងន់ ដ្បិតគោលទ្ធិនេះ មានសារៈ

ប្រយោជន៍ខ្លាំងណាស់។ នៅពេលសាវ័កប៉ុលស្នាក់នៅបីសប្តាហ៍ក្នុងទីក្រុងថែស្សាឡូនីច លោកតែងតែបង្រៀនពីព្រះអម្ចាស់យេស៊ូវរស់ពីសុគតឡើងវិញ។

អ្នកនៅទីក្រុងថែស្សាឡូនីច ទទួលព្រះអម្ចាស់យេស៊ូវជាអង្គសង្គ្រោះច្រើនគ្នាណាស់។

**ពួកអ្នកនោះខ្លះក៏យល់ព្រម ហើយបានចូលខាងប៉ុល នឹងស៊ីឡាស ព្រមទាំងពួកសាសន៍ក្រេកសន្ធឹក ដែលតែងតែថ្វាយបង្គំព្រះ នឹងពួកស្រីអ្នកមុខជាច្រើនដែរ (កិច្ចការ១៧:៤)។**

ប៉ុន្តែសូមកត់ចំណាំថា មិនមែនអ្នកនៅទីក្រុងនោះជឿទាំងអស់គ្នាទេ។ ធម្មតាអ្នកជឿដល់ព្រះយេស៊ូវ មានចំនួនតិចទេ។

បណ្ឌិតលូកាបញ្ជាក់ថា មានស្ត្រីសន្ធឹក ដែលជាអ្នកមុខអ្នកការជឿដល់ព្រះអម្ចាស់យេស៊ូវ។ ការនេះមានលក្ខណៈសំខាន់ណាស់។

**តែពួកសាសន៍យូដាដែលមិនព្រមជឿ គេមានចិត្តឈ្នានីស ក៏នាំយកមនុស្សពាលអនាថាខ្លះមក រួចប្រមូលបានមនុស្សយ៉ាងសន្ធឹក ទៅបង្កើតវឹកវរក្នុងទីក្រុង ហើយនាំគ្នាទៅចោមព័ទ្ធផ្ទះយ៉ាសុន**

**រកចាប់ប៉ុល នឹងស៊ីឡាស នាំចេញមកឯបណ្ដាជន (កិច្ចការ ១៧:៥)។**

នៅក្នុងចំណោមមនុស្សដែលឮដំណឹងល្អ មានអ្នកខ្លះជឿដល់ព្រះអង្គ ប៉ុន្តែមានអ្នកខ្លះមិនព្រមជឿដោយសារមានចិត្តឈ្នានីស។ នៅក្នុងក្រុមជំនុំរបស់ព្រះអង្គសព្វថ្ងៃ ក៏យ៉ាងដូច្នោះដែរ មានអ្នកខ្លះជឿព្រះអង្គ តែអ្នកខ្លះទៀតបន្លំខ្លួនធ្វើជាអ្នកជឿដើម្បីឈ្នានីសបំបែកបំបាក់ក្រុមជំនុំរបស់ព្រះយេស៊ូវ។

**លុះរកមិនឃើញ ក៏ចាប់យ៉ាសុន នឹងពួកជំនុំខ្លះ កន្ត្រាក់ដឹកនាំទៅដាក់នៅមុខចៅហ្វាយទីក្រុងដោយស្រែកថា ពួកដែលនាំឱ្យក្រឡាប់ផែនដីនោះ បានមកទីនេះហើយ (កិច្ចការ១៧:៦)។**

បណ្ឌិតលូកាបញ្ជាក់ថា មនុស្សដែលមានចិត្តឈ្នានីស គេចោទសាវ័កប៉ុលនិងគូកនរបស់លោកថាជាអ្នក "បង្កើតវឹកវរក្នុងទីក្រុង"។ ត្រង់នេះ អ្នកចោទប្រកាន់និយាយត្រូវហើយ។ អ្នកនៅទីក្រុងថែស្សាឡូនីចមានការជ្រួលច្របល់មែន។ ធម្មតាអាណាចក្រដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់សាសន៍រ៉ូម មិនអាចនិយាយស្ដីអ្វីបានទេ។ ឥឡូវនៅពេលដែលសាវ័កប៉ុលយកដំណឹងល្អទៅបង្ហាត់បង្រៀនដល់មនុស្សនៅក្នុងទីក្រុងថែស្សាឡូនីច ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់សាសន៍រ៉ូម មនុស្ស

នាំគ្នាប្រែចិត្តមកដើរតាមសេចក្តីពិត។ ដូច្នេះ ហើយបានជាអ្នកស្រុកនៅទីក្រុងនោះ ចាប់យកសេចក្តីពិតមកអនុវត្តនៅក្នុងជីវិតខ្លួន។

សព្វថ្ងៃនៅក្នុងពិភពលោក យើងមិនឃើញថាមានចលនាបដិវត្តន៍ឆ្ពោះមករក គំនិតត្រឹមត្រូវដូចដំណឹងល្អរបស់ព្រះអម្ចាស់យេស៊ូវទេ។ បើបែរជាគេនាំគ្នាងើបធ្វើបដិវត្តន៍វិញ គេនាំគ្នាធ្វើបដិវត្តន៍បំផ្លាញប្រទេសតែម្តង។ ដំណឹងល្អរបស់ព្រះអម្ចាស់យេស៊ូវ ត្រូវតែជាដំណឹងល្អដែលញ៉ាំងអោយចិត្តមនុស្សធ្វើការបដិវត្តន៍ចាកចេញពីអំពើអាក្រក់របស់ខ្លួន។ មិនយ៉ាងដូច្នោះទេ សូម្បីអ្នកជឿដល់ព្រះអម្ចាស់យេស៊ូវសព្វថ្ងៃ ក៏មានអ្នកបន្ទំខ្លួនធ្វើបដិវត្តន៍អោយព្រះរាជសាររបស់ព្រះអម្ចាស់យេស៊ូវត្រូវថោកទាប ដោយសារការប្រព្រឹត្តរបស់ខ្លួនដែរ។ ការបន្ទំខ្លួនធ្វើជាគ្រីស្ទបរិស័ទ ពិតជាធ្វើអោយព្រះនាមព្រះអង្គសាបរលាបមែន។ យើងខ្ញុំសូមអំពាវនាវដល់គ្រីស្ទបរិស័ទដែលស្រឡាញ់ដល់ព្រះអម្ចាស់យេស៊ូវ ព្រមទាំងមានគំនិតចង់រស់នៅជំកើងព្រះអម្ចាស់យេស៊ូវរៀងរាល់ថ្ងៃ មេត្តាព្យាយាមហាត់លុតពុតទាំងខ្លួន ទាំងចិត្តអោយដើរតាមព្រះអម្ចាស់យេស៊ូវ ព្រមទាំងលើកតម្លៃព្រះបន្ទូលនៅក្នុងជីវិតរបស់ខ្លួន ក៏ដូចជាការប្រព្រឹត្តប្រចាំថ្ងៃនៅក្នុងជីវិតផងដែរ។ កិរិយាប្រព្រឹត្តបែបនេះ រាប់ថាជាកិរិយាបដិវត្តន៍ដើរឆ្ពោះទៅកាន់សេចក្តីពិត និងជីវិតថ្លៃថ្នូរក្នុងការរស់នៅក្នុងសង្គម។

**៧ឯយ៉ាសុននេះ ជាអ្នកបានទទួលគេ ពួកនោះប្រព្រឹត្តសុទ្ធតែខុសនឹងបញ្ញត្តរបស់សេសារ ដោយនិយាយថា មានស្តេច១ទៀត**

**ឈ្មោះយេស៊ូវ ៨ មនុស្សទាំងនោះក៏នាំឱ្យអស់បណ្តាជន នឹងចៅ**
**ហ្វាយនៃទីក្រុងកើតចារម្ភព្រួយ ដោយឮសេចក្តីនោះ ៩ រួចកាល**
**បានយកប្រាក់ធានាពីយ៉ាសុន នឹងអ្នកឯទៀតហើយ នោះក៏លែង**
**គេចេញទៅ (កិច្ចការ១៧:៧-៩)។**

សូមនឹកចាំថា ទឹកដីដែលសាវ័កប៉ុលកំពុងផ្សព្វផ្សាយដំណឹងល្អនេះ ស្ថិតនៅក្រោមអំណាចគ្រប់គ្រងរបស់សាសន៍រ៉ូម។ ច្បាប់ដែលគេយកមកប្រើដើម្បីគ្រប់គ្រងផែនដីសម័យនោះ គឺជាច្បាប់របស់ស្តេចសេសារ។ នៅពេលដែលគេចាប់លោកយ៉ាសុនអោយបង់ប្រាក់ មានន័យថា លោកយ៉ាសុនត្រូវបង់ប្រាក់ធានារ៉ាប់រងថា មិនអោយមាននរណានិយាយពីរឿងព្រះអម្ចាស់យេស៊ូវនៅទីនោះទៀតទេ។

## កិច្ចការសាវ័កប៉ុលនៅក្រុងបេរា

**ពួកជំនុំក៏ឱ្យប៉ុល នឹងស៊ីឡាស ចេញទៅឯក្រុងបេរា ទាំងយប់ភ្លាម កាលទៅដល់ នោះគេចូលទៅក្នុងសាលាប្រជុំរបស់ពួកសាសន៍យូដា (កិច្ចការ១៧:១០)។**

ការបៀតបៀនទាំងអម្បាលមាណខាងលើ មិនបានធ្វើអោយកិច្ចការរបស់សាវ័កប៉ុលត្រូវអន់ថយឡើយ។ លោកធ្វើដំណើរទៅដល់ក្រុងបេរា គឺជាទីក្រុងដែលស្ថិតនៅជិតទីក្រុងថែស្សាឡូនីចដែរ។

> **រីឯពួកអ្នកស្រុកនោះ មានចិត្តល្អជាងពួកអ្នកនៅថែស្សាឡូនីច គេប្រុងប្រៀបសព្វគ្រប់នឹងទទួលព្រះបន្ទូល ក៏ពិចារណាមើលគម្ពីររាល់តែថ្ងៃ ឲ្យបានដឹងជាសេចក្ដីទាំងនោះត្រូវឬមិនត្រូវ (កិច្ចការ ១៧:១១)។**

អ្នកនៅទីក្រុងបេរា ពិនិត្យមើលព្រះគម្ពីរ ពេលដែលសាវ័កប៉ុលកំពុងអធិប្បាយ។ ក្រុមជំនុំតូចមួយបានកើតឡើងនៅក្នុងទីក្រុងនេះ។ អ្នកស្រុកនាំគ្នាគាបសង្កត់ពួកអ្នកជឿនៅក្នុងទីក្រុងបេរា។ ប៉ុន្តែដោយសារការនោះ ក្រុមជំនុំនៅទីក្រុងបេរាមានកម្លាំងខ្លាំងក្លា។ បើតាមយើងសង្កេតមើល ក្រុមជំនុំរបស់ព្រះដែលមានពេញលេញច្រើនតែជាក្រុមជំនុំដែលទទួលការបៀតបៀនពីអ្នកដទៃ។ ដូច្នេះ ការបៀតបៀន ការគាបសង្កត់ ការធ្វើទុក្ខបុកម្នេញដល់ពួកអ្នកជឿព្រះអម្ចាស់យេស៊ូវ ជាការមានសារៈសំខាន់ជាទីបំផុត ដើម្បីអោយក្រុមជំនុំរបស់ព្រះអង្គមានលក្ខណៈល្អប្រសើរឡើង។ ការបណ្ដោយអោយគ្រីស្ទបរិស័ទមានសេរីភាពហួសខ្នាត ជាការធ្វើអោយក្រុមជំនុំរបស់ព្រះអង្គ មានអំពើពុករលួយកាន់តែច្រើនឡើងវិញទេ។

**ដូច្នេះ មានពួកគេ នឹងពួកស្រីសាសន៍ក្រេក ជាអ្នកមុខអ្នកការជាច្រើនបានជឿ ក៏មានប្រុសៗក្រែលដែរ (កិច្ចការ១៧:១២)។**

បណ្ឌិតលូការៀបរាប់ថា មានមនុស្សសន្ធឹកណាស់ជឿដល់ព្រះអង្គ។ ឯអ្នកដែលជឿដល់ព្រះអង្គទាំងនោះ សុទ្ធតែជាអ្នកធំផង។

**១៣ តែកាលពួកសាសន៍យូដានៅថែស្សាឡូនីចបានដឹងថា ប៉ុលបាន
ផ្សាយព្រះបន្ទូលក្នុងក្រុងបេរាដែរ នោះគេក៏មកញុះញង់បណ្តាជន
នៅទីនោះទៀត
១៤ ដូច្នេះ ពួកជំនុំឱ្យប៉ុលចេញទៅភ្លាម ធ្វើដូចជា
នឹងទៅឯសមុទ្រ តែស៊ីឡាស នឹងធីម៉ូថេ នៅទីនោះតទៅ
(កិច្ចការ១៧:១៣-១៤)។**

នៅពេលនេះ សាវ័កប៉ុលចេញពីទីក្រុងបេរា តែម្នាក់ឯងគត់។

## កិច្ចការសាវ័កប៉ុលនៅក្រុងអាថែន

**ឯពួកអ្នកដែលជូនប៉ុលទៅ គេនាំទៅឯក្រុងអាថែនវិញ រួចកាលគេទទួលពាក្យ ដែលគាត់ផ្តាំទៅស៊ីឡាស នឹងធីម៉ូថេ ឱ្យគេមកចួប**

**នឹងគាត់ជាប្រញាប់ នោះគេនាំគ្នាត្រឡប់វិលទៅវិញ (កិច្ចការ ១៧:១៥)។**

នៅពេលដែលលោកធ្វើដំណើរទៅដល់ទីក្រុងអាថែន សាវ័កប៉ុលស្នាក់នៅទីនោះ ដើម្បីរង់ចាំលោកស៊ីឡាស និងធីម៉ូថេ។ លោកចង់ដឹងដំណឹងអំពីស្ថានភាពរបស់ក្រុមជំនុំនៅទីក្រុងថែស្សាឡូនីច និងទីក្រុងបេរា។

**កំពុងដែលប៉ុលចាំគេនៅក្រុងអាថែន នោះគាត់មានសេចក្តីរំជួលក្នុងចិត្តជាខ្លាំង ដោយឃើញមានរូបព្រះនៅពេញក្នុងទីក្រុងនោះ (កិច្ចការ១៧:១៦)។**

ទីក្រុងអាថែន គឺជាមជ្ឈមណ្ឌលវប្បធម៌របស់សកលលោក នៅក្នុងសម័យនោះ។ ប៉ុន្តែទោះជាទីក្រុងនោះ ជាទីក្រុងរបស់អ្នកចេះដឹងក៏ដោយ ក៏មានរូបព្រះរាប់រយរាប់ពាន់មុខដាក់តម្កល់ទុកនៅទីនោះដែរ។

**ដូច្នេះ គាត់ក៏ជជែកពន្យល់ដល់សាសន៍យូដា នឹងពួកអ្នកដែលថ្វាយបង្គំក្នុងសាលាប្រជុំគេ ហើយនៅទីផ្សារ ជាមួយនឹងអស់អ្នកដែលមកចួបនឹងគាត់រាល់តែថ្ងៃដែរ (កិច្ចការ១៧:១៧)។**

សាវ័កប៉ុលធ្វើដំណើរផ្សាយដំណឹងល្អបណ្តើរ លក់ត្រសាលចិញ្ចឹមជីវិតបណ្តើរ។ ខ្ញុំជឿថា លោកលក់ត្រសាលដាច់បានខ្លះដែរ នៅក្នុងទីក្រុងអាថែន កំពុងតែលោកផ្សាយដំណឹងល្អពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ របររកស៊ីលក់ត្រសាលរបស់លោកធ្វើអោយមនុស្សចាប់ចិត្តជាខ្លាំង។

> **តែមានពួកអេពីគួរ នឹងពួកស្ទូអ៊ីកខ្លះ ជាអ្នកប្រាជ្ញបរមត្ថ គេមកចួបនឹងគាត់ ខ្លះសួរថា តើអ្នកដែលនិយាយប៉ប៉ាច់នេះចង់ថាដូចម្តេច ខ្លះទៀតថា មើលទៅដូចជាគាត់សំដែងពីព្រះដទៃទេ ដ្បិតឮគាត់ប្រាប់គេពីព្រះយេស៊ូវ ហើយពីសេចក្តីរស់ពីស្លាប់ឡើងវិញ (កិច្ចការ១៧:១៨)។**

ពួកអេពីគួរ គឺជាទស្សនវិទូដែលគេបង្រៀនថា ដើម្បីបំបាត់ការអាក្រក់ មនុស្សត្រូវធ្វើការអាក្រក់អោយបានច្រើនជាអតិបរមា។ ឧទាហរណ៍ពីរឿងផឹកស្រាទៅចុះ។ ទស្សនវិទូអេពីគួរ បង្រៀនថា ដើម្បីអោយមនុស្សឈប់ផឹកស្រា មនុស្សត្រូវផឹកស្រាអោយអស់ពីហាង។ បើមនុស្សចង់អោយមនុស្សរៀងចាលពីអំពើកាមគុណ ត្រូវអោយប្រព្រឹត្តអំពើកាមគុណអោយអស់ពីសមត្ថភាពដែលខ្លួនអាចធ្វើទៅបាន។ ឯពួកស្ទូអ៊ីកវិញ មិនជឿយ៉ាងដូច្នេះទេ គឺគេត្រូវបង្ក្រាបរូបកាយកុំអោយធ្វើតាមតណ្ហាដែលខ្លួនចង់ធ្វើឡើយ។ ពួកស្ទូអ៊ីកបង្រៀនដូចសុភាសិតខ្មែរយើងថា "កុំស៊ីតាមឃ្លាន

កុំហ៊ានតាមចង់។

ពួកទស្សនវិទូទាំងពីរក្រុម នាំគ្នាស្តាប់លោកប៉ុលអធិប្បាយយ៉ាងយកចិត្តទុកដាក់។ គេដាក់ងារលោកប៉ុលថាជាមនុស្សនិយាយប៉ប៉ាច់ប៉ប៉ោច។ មិនតែប៉ុណ្ណោះ គេនិយាយថា ព្រះយេស៊ូវដែលរស់ពីសុគតឡើងវិញ ជាព្រះសែនមហាចម្លែក។ ប៉ុន្តែទោះជាយ៉ាងនោះក៏ដោយ គេចូលចិត្តស្តាប់សេចក្តីអធិប្បាយរបស់សាវ័កប៉ុលណាស់។

**គេក៏នាំយកគាត់ទៅឯភ្នំអើរីយ៉ូសស្សួរថា តើយើងអាចនឹងដឹងជាសេចក្តីបង្រៀនថ្មី ដែលអ្នកអធិប្បាយនេះជាយ៉ាងណាបានឬទេ (កិច្ចការ១៧:១៩)។**

ពួកអ្នកនៅទីក្រុងថែស្សាឡូនីចដែលឮដំណឹងល្អរបស់ព្រះអម្ចាស់យេស៊ូវ មិនខុសអំពីមនុស្សសម័យសព្វថ្ងៃនេះទេ។ មនុស្សខ្លះឮដំណឹងល្អហើយ និយាយថា គេមិនចាំបាច់ត្រូវការដំណឹងល្អ ឬអាក្រក់អីរបស់ព្រះយេស៊ូវទេ។ លោកអ្នកបងប្អូនអើយ បើមនុស្សក្រៅក្រុមជំនុំមិនយល់ថា ដំណឹងល្អរបស់ព្រះយេស៊ូវមិនមានសារៈសំខាន់សម្រាប់គេ នោះជារឿងធម្មតា។ ប៉ុន្តែបើអ្នកនៅក្នុងពួកជំនុំ បែរជាយល់ថា ដំណឹងល្អរបស់ព្រះយេស៊ូវមិនមានអំណាចមកលើខ្លួនទេ ជារឿងមួយគួរអោយអកុសលណាស់។ មនុស្សគ្រប់រូប ទោះអ្នកនៅក្នុងក្រុមជំនុំ ឬក្រៅក្រុមជំនុំក្តី ត្រូវដឹងថាខ្លួនមានបាប។ មនុស្សគ្រប់រូប ត្រូវការព្រះអម្ចាស់យេស៊ូវយាងមកសុគតជំនួសអំពើបាបរបស់គេ។

បើគេជឿដល់ព្រះអម្ចាស់យេស៊ូវ នោះជីវិតរបស់គេពិតជាមានខ្លឹមសារនៅក្នុងលោក នេះ ក៏ដូចជានៅក្នុងបរលោកនាយដែរ។

> **២០ ដ្បិតយើងបានឮអ្នកអធិប្បាយយ៉ាងប្លែកណាស់ ដូច្នេះ យើងចង់
> ដឹងន័យសេចក្តីទាំងនេះដែរ ២១ រីឯពួកអ្នកនៅក្រុងអាថែន នឹង
> ពួកអ្នកប្រទេសក្រៅដែលមកស្នាក់នៅទាំងប៉ុន្មាន គេមិនដែលបង់
> ពេលទំនេរនឹងធ្វើអ្វីទៀតទេ គេគិតតែពីប្រាប់ ឬស្តាប់សេចក្តីថ្មី
> ប៉ុណ្ណោះ (កិច្ចការ១៧:២០-២១)។**

សព្វថ្ងៃមនុស្សខ្លះដែលរស់នៅក្នុងលោកនេះ ខំរៀនសូត្របង្ហាញអោយអ្នកដទៃយល់ថា ខ្លួនមានប្រាជ្ញាចេះដឹងខ្ពង់ខ្ពស់។ តើពូជរបស់មនុស្សដែលមានគំនិតបែបនេះ ចាប់ផ្តើមពីត្រឹមណាមក? ពូជរបស់មនុស្សដែលអួតអាង មានតាំងពីជំនាន់មនុស្សនៅទីក្រុងអាថែនម្ល៉េះ។

មនុស្សជំនាន់សព្វថ្ងៃនេះ គេតែងគិតថាចេះដឹងជាងមនុស្សសម័យមុន។ កាលណានិយាយអំពីវិទ្យាសាស្ត្រ អំពីកុំព្យូទ័រ គេថាជាចំណេះវិជ្ជាថ្មី។ ប៉ុន្តែចំណេះវិជ្ជាថ្មីមិនមែនទើបនឹងមានឥឡូវនេះទេ ពោលគឺចំណេះវិជ្ជាថ្មី មានតាំងពីដើមមក។ អ្នកទីក្រុងអាថែនយល់ថា គេជាអ្នកចេះណាស់។ ប៉ុន្តែទោះបីគេចេះយ៉ាងដូច្នោះក៏ដោយ គេនាំគ្នាអោយតម្លៃដល់សាវ័កប៉ុលថា សេចក្តីអធិប្បាយពីដំណឹងល្អ ដែលថាព្រះអម្ចាស់

យេស៊ូវយាងមកសុគតហើយរស់ឡើងវិញ គឺជាចំណេះថ្មីជាងគេបង្អស់ ដែលគេមិនដែលបានស្គាល់នៅក្នុងការសិក្សារបស់គេកន្លងមក។

យើងស្លេះការសិក្សាគម្ពីរកិច្ចការត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"